បុរី
ចន្ទគិរី
BOREY CHANKIRI
BY URBANLAND

# គម្រោងទី 2



ជីវិតយើងគ្រប់រូបតែងមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយទីតាំងដែលយើងប្រើប្រាស់ប្រចាំថ្ងៃរួមមាន គេហដ្ឋាន កន្លែងធ្វើការ កន្លែងកម្សាន្ត និងទីធ្លាសហាគមន៍ផ្សេងៗ។ ក្នុងនោះ ផ្ទះគឺជាកន្លែងសំខាន់បំផុតដែលយើងចំណាយពេលវេលាច្រើនជាងគេនិងមានឥទ្ធិភាពយ៉ាងធំធេងទៅលើគុណភាពនៃជីវិតយើងទាំងមូល។

នៅបុរីចន្ទគីរី  ផ្ទះនីមួយៗត្រូវបានរចនាឡើងយ៉ាងយកចិត្តទុកដាក់ ដោយកត្តាម្ចាស់ផ្ទះត្រូវបានដាក់ចូលជាចំណុចស្នូលនៃការរចនាប្លង់។ តម្រូវការរបស់លោកអ្នកក្នុងការប្រើប្រាស់លំនៅដ្ឋានត្រូវបានសិក្សាស្វែងយល់យ៉ាងលម្អិត រួមជាមួយគោលគំនិតក្នុងការផ្សារភ្ជាប់អ្នករស់នៅគេហដ្ឋាន បរិស្ថានជុំវិញផ្ទះ ជាមួយនឹងប្លង់មេដែលហ៊ុមពន្ធ័ដោយធម្មជាតិ។

យើងប្តេជ្ញាចិត្តសាងសង់ផ្ទះ ដែលលោកអ្នកអាចរស់នៅប្រាស្រ័យទាក់ទងជាមួយក្រុមគ្រួសារយ៉ាងស្និទ្ធស្នាល ជាកន្លែងសម្រាកលម្ហែកាយបន្ធូរអារម្មណ៍នៅពេលទំនេរ និងឱកាស   ក្នុងការបង្កើតអត្តសញ្ញាណផ្ទាល់ខ្លួន ដើម្បីភាពលូតលាស់ រីកចម្រើនកាន់តែប្រសើរ។ ជាពិសេស យើងសង្ឃឹមថា លោកអ្នក និងក្រុមគ្រួសារ នឹងមានមោទនភាពក្នុងភាពជាម្ចាស់ផ្ទះនៃបុរីចន្ទគីរី។

បុរីចន្ទគីរី គម្រោងទី 2 មានការរចនាយ៉ាងសម្រិតសម្រាំង ដើម្បីបង្កើនគុណភាពជីវិត និងការរស់នៅក្នុងសហគមន៍មួយប្រកបដោយផាសុកភាព។ បុរីចន្ទគីរី គម្រោងទី 2 ស័ក្តិសមបំផុតសម្រាប់លោកអ្នកដែលត្រូវការភាពងាយស្រួលបែបជីវិតក្នុងទីក្រុងផងនិងការរស់នៅស្ងប់ស្ងាត់បែបសហគមន៍ផង។

បុរីចន្ទគីរី គម្រោងទី 2 គឺជាបុរី និងផ្ទះអាជីវកម្មថ្មីជាប់មាត់ទឹកនៅភាគខាងត្បូងនៃទីក្រុងភ្នំពេញ ចម្ងាយត្រឹមតែ 500m ពីផ្លូវជាតិលេខ 2 និងស្ថិតនៅតាមបណ្តោយមាត់ស្ទឹងព្រែកត្នោត។ បុរីចន្ទគីរី គម្រោងទី 2 ជាគេហដ្ឋានដ៏ល្អឥតខ្ចោះសម្រាប់គ្រួសារអ្នក។

**រចនាឡើងដើម្បីការរស់នៅប្រសើរជាងមុន**




## សូមស្វាគមន៍មកកាន់

# បុរីចន្ទគីរី គម្រោងទី 2

បុរី
ចន្ទគីរី
BOREY CHANKIRI
BY URBANLAND





## សហគមន៍បង្កើតឡើង ដោយការបំផុសគំនិតពីធម្មជាតិ

ការរចនារបស់យើងមានការបំផុសគំនិតចេញពីរុក្ខវិថីដែលមានដើមឈើដុះត្រឈឹងត្រឈៃតាមមាត់ទឹក និងមានគោលបំណងដើម្បីបង្កើតសហគមន៍រស់នៅកាន់តែប្រសើរជាងមុននៅក្បែរធម្មជាតិ។ រាល់ពេលដែលលោកអ្នកមកដល់ផ្លូវចូលបុរីចន្ទគីរី លោកអ្នកនឹងទទួលអារម្មណ៍ស្ងប់ស្ងាត់ និងសុខស្រួលភ្លាមៗជាមួយទេសភាពតាមដងស្ទឹង ឃ្លាតចាកពីភាពនឿយហត់នៃការងារ និងភាពមមាញឹកនៅក្នុងទីក្រុង។



## ច្រកចូលទៅកាន់ភាពស្ងប់ស្ងាត់

គ្រាន់តែបោះជំហានមកដល់ច្រកចូលនៃបុរីចន្ទគីរីភ្លាម ភាពស្មុគស្មាញប្រចាំថ្ងៃនឹងរលាយបាត់មួយរំពេចជាមួយទិដ្ឋភាពសួនបៃតងស្រស់បំព្រង។ ច្រកចូលបុរីចន្ទគីរី ត្រូវបានរចនាបែបសាមញ្ញដើម្បីស្វាគមន៍ និងផ្តល់នូវអារម្មណ៍កក់ក្តៅពេលលោកអ្នកត្រឡប់មកដល់គេហដ្ឋានវិញ។





## ប្លង់មេបានរចនាឡើងដើម្បីនាំយក ធម្មជាតិមកកាន់ជីវិតប្រចាំថ្ងៃ

ប្លង់មេបុរីចន្ទគីរី គម្រោងទី 2 ត្រូវបានរចនាឡើងយ៉ាងយកចិត្តទុកដាក់ដើម្បីបង្កើតនូវសហគមន៍រស់នៅដ៏រស់រវើកមួយ ដែលមិនត្រឹមតែផ្តល់នូវសោភ័ណភាពធម្មជាតិប៉ុណ្ណោះទេប៉ុន្តែថែមទាំងជម្រុញឱ្យមានសកម្មភាពនៅខាងក្រៅ ការជួបជុំបែបគ្រួសារ និងមិត្តភក្តិប្រកបដោយភាពជិតស្និទ្ធ។ យើងបង្កើតសួនបៃតងតូចៗ ទីធ្លាប្រើប្រាស់បរិក្ខាររួម និងផ្លូវថ្មើរជើងជាច្រើន គិតចាប់ពីមាត់ច្រកចូលបុរីរហូតដល់ច្រកម្ខាងទៀត ដែលស្ថិតនៅ

# រចនាបថទាំង 32
# នៃប្លង់មេ បុរីចន្ទគីរី គម្រោងទី 2




### តំបន់សិក្សាស្វែងយល់

ត្រូវបានរចនាសម្រាប់លោកអ្នកដែលស្វែងរកកន្លែងស្ងប់ស្ងាត់ ផ្តាច់ចេញពីភាពអ៊ូអរប្រចាំថ្ងៃ និងភ្ជាប់ទំនាក់ទំនងជាមួយខ្លួនឯង និងធម្មជាតិសារជាថ្មី ។

### តំបន់សេនត្រល

ជាចំនុចកណ្តាលនៃប្លង់មេ និងជាសួនធម្មជាតិដ៏ធំដែលមានបណ្តុំសួនតូចៗ សម្រាប់សមាជិកគ្រួសារគ្រប់វ័យក្នុងការជួបជុំកម្សាន្ត នៅក្រៅផ្ទះ។

### តំបន់ច្រកចូល

ជាទីតាំងនៅខាងមុខនៃប្លង់មេ រចនាឡើងដើម្បីទទួលស្វាគមន៍មនុស្សគ្រប់គ្នាជាមួយនឹងសម្រស់ទេសភាពធម្មជាតិ។

1. បរិវេណជួបជុំច្រកចេញចូល
Gateway Plaza
2. ច្រកចេញចូល & ប៉ុស្តិ៍សន្តិសុខ
Gateway & Guardhouse
3. ផ្លូវដើរព្រៃរុក្ខជាតិ
Forest Trialhead
4. ផ្លូវដើរព្រៃទឹកភ្លៀង
Rainforest Trail
5. ទីធ្លាលេងកីឡា
Game Corner
6. ទីធ្លាពិសារអាហារក្រៅផ្ទះ
Outdoor Dining
7. មហាវិថីសេនត្រល
Central Boulevard
8. ផ្លូវដើរសេនត្រល
Central Walk
9. សួនបៃតងសេនត្រល
Central Park
10. ទីធ្លាជួបជុំសេនត្រល
Central Square
11. វាលស្មៅព្រះអាទិត្យ
Sunny Lawn
12. កញ្ចុះលម្ហែកាយ
Social Pavilion
13. អាងទឹកធ្លាក់
Cascading Pool
14. អាងទឹកថ្មលម្អ
Rock Pool
15. ស្ពានសួនសេនត្រល
Central Park Bridge
16. អាងទឹកត្រាំជើង
Dipping Pool
17. ឆ្នេរពិកនិក
Picnic Shore
18. ផ្លូវម៉ាស្សាបាតជើងផ្ទាល់ដី
Dry Reflexology Path
19. ផ្លូវម៉ាស្សាបាតជើងក្នុងទឹក
Wet Reflexology Path
20. ទីធ្លាហាត់ប្រាណមនុស្សវ័យចំណាស់
Senior Fitness Corner
21. សួនកម្សាន្តកុមារ
Kid's Playground
22. ផ្លូវលម្អសិក្សាស្វែងយល់ និងវិទ្យាសាស្ត្រសម្រាប់កុមារ / Discovery Passage
23. ទីធ្លាហាត់ប្រាណ
Adult Fitness Area
24. សួនផ្កាក្រអូប
Scented Garden
25. ច្រកថ្មើរជើង
Side Gateway
26. បណ្ណាគារសហគមន៍
Community Library
27. ផ្លូវសួនលម្អ សម្រាប់សិក្សាពីរុក្ខជាតិ
Nature Discovery Walk
28. សួនពិសារតែ
Tea Garden
29. ទីធ្លាសួនព្រៃរុក្ខជាតិ
Forager’s Forest
30. សួនសហគមន៍
Community Garden
31. រោងដាំរុក្ខជាតិ
Garden Shed
32. ច្រកចេញចូលខាងក្រោយ
Rear Gateway



## សួនសេនត្រលផាកសម្រាប់មនុស្សគ្រប់គ្នា

សួនសេនត្រលផាក គឺជាសួនជួបជុំដ៏ធំទូលាយសម្រាប់សមាជិកគ្រួសារគ្រប់វ័យ ដែលលើកទឹកចិត្តឱ្យមានសកម្មភាពកម្សាន្តក្រៅផ្ទះ សម្រាប់លោកអ្នក កូនៗ និងឪពុកម្តាយវ័យចំណាស់ ការជួបជុំមិត្តភ័ក្តិ ឬអ្នកជិតខាងនៅក្នុងទីធ្លាដែលហ៊ុមព័ទ្ធដោយរុក្ខជាតិបៃតងស្រស់បំព្រង។







## គេហដ្ឋានរចនាឡើងបែប “ល្អគន់ មិនមែនល្អឆើត”

ពោល គឺមើលកាន់តែយូរ កាន់តែស្រស់ស្អាត មិនងាយជិនណាយ រស់នៅកាន់តែយូរ ជីវិតកាន់តែប្រសើរជាងមុន ដោយគ្រប់ជ្រុងទាំងអស់នៃផ្ទះសុទ្ធសឹងតែរចនាឡើងដើម្បីបំពេញតម្រូវការរបស់ម្ចាស់ផ្ទះ មានភាពសាមញ្ញស្រស់ស្អាតបែបល្អគន់ និងធានាឱ្យបាននូវភាពគង់វង្សយូរអង្វែងដល់កូនចៅជំនាន់ក្រោយរបស់លោកអ្នក។

## គេហដ្ឋានមានការរចនាក្នុងគោលគំនិត “ខ្លឹម”

**ពោល គឺការប្រកាន់ខ្ជាប់នូវគុណភាព ភាពឋិតថេរ និងភាពផ្ចិតផ្ចង់នៃគ្រប់សំណង់ផ្ទះនីមួយៗជាចម្បង។ យើងបង្កើតការរចនាដែលមានគោលបំណង និងមុខងារច្បាស់លាស់ មានពន្លឺធម្មជាតិ ខ្យល់អាកាសបរិសុទ្ធចេញចូលគ្រប់គ្រាន់ ដើម្បីធ្វើឱ្យការរស់នៅរបស់លោកអ្នកកាន់តែប្រសើរជាងមុន។**





## ការរចនាផ្ទះផ្នែកខាងក្នុងផ្សារភ្ជាប់នឹងធម្មជាតិនៅខាងក្រៅ



យើងរចនាគេហដ្ឋានដោយរួមបញ្ចូលធម្មជាតិជាមួយការរស់នៅប្រចាំថ្ងៃ។ គេហដ្ឋាននៅបុរីចន្ទគីរី ផ្តល់ពន្លឺធម្មជាតិគ្រប់គ្រាន់ មានចរន្តខ្យល់បរិសុទ្ធ និងស្ថិតនៅជាប់សួនរុក្ខជាតិបៃតង ជួយឱ្យការរស់នៅកាន់តែមានភាពស្រស់ស្រាយ។ គិតចាប់ពីការរៀបចំរចនាបថ និងជ្រើសរើសពណ៌ យើងផ្តោតសំខាន់លើការបង្កើនភាពកក់ក្តៅ ផាសុកភាព និងប្រណិតភាពសម្រាប់ម្ចាស់ផ្ទះ។





## ពេលវេលាមានតម្លៃជាមួយអាហារចម្អិននៅផ្ទះ

ស្របពេលដែលជីវិតយើងកាន់តែមានភាពមមាញឹក ការចម្អិនអាហារ និងការញ៉ាំអាហារជុំគ្នា បានក្លាយជាពេលវេលាដ៏មានតម្លៃសម្រាប់គ្រួសារ។ យើងស្តាប់មតិយោបល់របស់ម្ចាស់ផ្ទះយ៉ាងយកចិត្តទុកដាក់ ដើម្បីធានាឱ្យបាននូវការរចនាដែលបំពេញតម្រូវការមួយនេះ ដោយមានការរចនាផ្ទះបាយបើកចំហថ្មីរបស់យើង។ ការរចនាផ្ទះបាយបើកចំហថ្មីនេះ អនុញ្ញាតឱ្យលោកអ្នកចំណាយពេលវេលាមានតម្លៃក្នុងការចម្អិន និងញ៉ាំអាហារជុំគ្នានៅផ្ទះ។ រីឯកន្លែងទទួលទានអាហារមានភាពប្រណិតធំទូលាយសម្រាប់គ្រួសារ និងមិត្តភក្តិដែលបន្ថែមរសជាតិដល់ជីវិតមួយកម្រិតទៀត។

## ផ្ទះអាជីវកម្ម

ស្ថិតនៅលើផ្លូវចូល និងផ្លូវចំហៀងបុរី ផ្តល់ភាពងាយស្រួលដល់អ្នករស់នៅក្នុងបុរី អ្នកធ្វើដំណើរ និងសហគមន៍នៅជុំវិញតំបន់។






## ផ្ទះអាជីវកម្មសម្រាប់សហគមន៍ទាំងក្នុង និងក្រៅបុរី

ផ្ទះអាជីវកម្មនៅបុរីចន្ទគីរី គម្រោងទី 2 បានរចនាឡើងមានភាពបត់បែនសមស្របតាមតម្រូវការប្រើប្រាស់របស់លោកអ្នក ដោយមានជាន់ផ្ទាល់ដីសម្រាប់ការធ្វើអាជីវកម្មផ្សេងៗ និងជាន់ខាងលើអាចកែច្នៃជាការិយាល័យ ឬកន្លែងរស់នៅប្រកបដោយផាសុកភាព និងភាពងាយស្រួលបំផុត។ ផ្ទះអាជីវកម្មរបស់យើងស្ថិតនៅជាប់មាត់ទឹក និងចំហៀងបុរី ដែលនៅក្បែរសហគមន៍ជុំវិញជាច្រើន ពិសេសបំផុតសម្រាប់លោកអ្នកដែលមានគម្រោងពង្រីកអាជីវកម្មនៅភាគខាងត្បូងនៃរាជធានីភ្នំពេញ។



# ទីតាំងសំខាន់ ជុំវិញបុរីចន្ទគីរី




## ផ្លូវតភ្ជាប់

**3 នាទី** ផ្លូវចម្ការដូង

**5 នាទី** មហាវិថីសម្តេច ហ៊ុន សែន (ផ្លូវ 60 ម៉ែត្រ)

**18 នាទី** មហាវិថីព្រះមុនីវង្ស (ស្ពានអាកាសព្រះមុនីវង្ស)

## ទីតាំងសំខាន់ៗ

**3 នាទី** រង្វង់មូលក្បូរស្រូវ

**13 នាទី** ក្រុងតាខ្មៅ

**15 នាទី** អាកាសយានដ្ឋានអន្តរជាតិតេជោ

## សេវាកម្ម និង ការរស់នៅប្រចាំថ្ងៃ

**1 នាទី** ផ្សារទំនើប ខេ ម៉ល ព្រែកត្នោត

**10 នាទី** ផ្សារទំនើប អ៊ីអន មានជ័យ

**10 នាទី** ផ្សារ 60M ខំម្យូនីធីម៉ល

**12 នាទី** ផ្សារទំនើប ឡាក់គី

**15 នាទី** ផ្សារទំនើប ជីប ម៉ុង មេហ្គាម៉ល 271

**20 នាទី** FACTORY VPHNOM PENH

## សាលារៀន និងមជ្ឈមណ្ឌលសិក្សា

**3 នាទី** សាលាប៊ែលធីអន្តរជាតិ

**13 នាទី** សាលាអន្តរជាតិភ្នំពេញ (ISPP)

**20 នាទី** សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

## ក្រុមហ៊ុនអភិវឌ្ឍ អឺបេនលែន

URBANLAND

ក្រុមហ៊ុន  អឺបេនលែន គឺជាក្រុមហ៊ុនអភិវឌ្ឍអចលនទ្រព្យក្នុងស្រុកមួយ បានបង្កើតឡើងនៅឆ្នាំ 2013 ដោយស្ថាបត្យករ លោក កាំង ហុក ដែលមានគោលដៅបង្កើតទីកន្លែងប្រកបដោយភាពច្នៃប្រឌិតខ្ពស់ ដើម្បីឱ្យមនុស្សគ្រប់គ្នារស់នៅ ធ្វើការ និងកម្សាន្ត ដោយប្តេជ្ញាលើ គុណភាព ភាពបិតថេរ និងភាពផ្ចិតផ្ចង់ ។ លោកជឿជាក់ថា ការផ្តោតលើតម្រូវការអ្នករស់នៅចម្បង គឺជាយុទ្ធសាស្ត្រដ៏ល្អបំផុត ដើម្បីជួយលើកកម្ពស់គុណភាពនៃការរស់នៅ និងបង្កើតបរិយាកាសប្រកបដោយផាសុកភាព។

ក្រុមហ៊ុន អឺបេនលែន មានមោទនភាពជាខ្លាំងដែលឆ្នាំនេះជាខួប 10 ឆ្នាំ នៃការរួមចំណែកក្នុងការអភិវឌ្ឍវិស័យអចលនទ្រព្យនៅប្រទេសកម្ពុជា។

## ក្រុមហ៊ុនអចលនទ្រព្យ ឈ្នះពានរង្វាន់




*Believe in Better.*

## ក្រុមហ៊ុនស្ថាបត្យកម្មដៃគូ

HKA + PARTNERS

## គម្រោងអភិវឌ្ឍដោយក្រុមហ៊ុន អឺបេនលែន

EMBASSY RESIDENCES

EMBASSY CENTRAL

TREELINE URBAN RESORT

K Mall

KMHPARK

KMHPARK 2

RAINTREE

# សូមអញ្ជើញមកកាន់ការិយាល័យលក់របស់បុរីចន្ទគីរី យើងខ្ញុំឥឡូវនេះ!

បើកដំណើរការជារៀងរាល់ថ្ងៃ
ចាប់ពីម៉ោង 8:00 ព្រឹកដល់ 5:00 ល្ងាច

ទីតាំងបុរីចន្ទគីរី

សម្រាប់ព័ត៌មានលម្អិត សូមទំនាក់ទំនង៖
**(+855) 61 888 580**
**(+855) 15 588 580**

សូមតាមដានបន្ថែម៖

បុរី ចន្លិគីរ
BOREY CHANKIRI
BY URBANLAND

URBANLAND | A MEMBER OF ISIGROUP